# អ្នកនាំសារ
The Messenger

22

ខែមេសា ឆ្នាំ២០០៥ តែងនីព្រះសហគមន៍កាតូលិក

# សួស្ដីឆ្នាំថ្មី



# កម្រងរូបថតពិធីបុណ្យចម្លង សប្ដាហ៍ពិសិដ្ឋ!

ព្រះសហគមន៍ផ្សារតូច នៅ
ភូមិកក្ដីញ





សកម្មភាពគ្រិស្ដបរិ
ស័ទព្រះសហគមន៍
កំពង់ទេះ និង
បញ្ញើ នៃមណ្ឌល
កំពង់ធំ នៅក្នុងភូមិ
ភាគពត់ំង









ព្រះសហគមន៍ភូមិកកំពង់ថម





















សកម្មភាព នៅក្នុព្រះសហ
គមន៍ ម្នាវ





លោកឪពុកគីស ព្រមនឹងបងប្អូនគ្រិស្ដបរិស័ទព្រះសហគមន៍ព្រៃស្វា កំពង់ធំ





ព្រះសហគមន៍ក្រុងព្រះសីហនុ



Photos: L. Sovanna, Fr. Omer, Channang

# ក្រុមកុមារកម្ពុជាលើក មុខមាត់ប្រទេសជាតិ

**មហាស្រពាលទាត់កុមារក្រោម ១៣ឆ្នាំ ប្រចាំឆ្នាំ២០០៥ របស់សហព័ន្ធបាល់ទាត់អាស៊ីត្រូវបានរៀបចំប្រកួតកាលពីថ្ងៃទី ១៥ ដល់ថ្ងៃទី ១៩ ខែមីនា។ ប្រទេសកម្ពុជាគឺជាម្ចាស់ផ្ទះ និងមានការចូលរួមពីប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី ម៉ាលឌីវ និងហ្វីលីពីន។ ក្រុមកុមារកម្ពុជាបានបង្ហាញសមត្ថភាពរបស់ខ្លួនមិនធ្លាប់មានពីមុនដែលមិនធ្លាប់តែចាញ់ៗ**



រូបតូចលើខាងស្តាំ ពេលចាប់ផ្តើមប្រកួត អាជ្ញាកណ្តាលកំពុងចេះកាក់ជ្រើសរើសទីលានៗ រូបធំ ទិដ្ឋភាពនៃការប្រកួតបាល់ទាត់របស់យុវជន អាយុក្រោម ១៣ឆ្នាំ រវាងកម្ពុជា និង ម៉ាឡេស៊ី នៅក្នុងថ្ងៃទី១។

Photo: Davith

ក្រោយពីបានមិនទទួលអស់ពេល ២ឆ្នាំមក នេះជាលើក ទី១ហើយ ដែលនៅពហុកីឡាដ្ឋានជាតិអូឡាំពិកក្នុងរាជធានីភ្នំពេញ មានរៀបចំកម្មវិធីប្រកួតកីឡា ជាផ្លូវការ។ នេះគឺជាមហាស្រពាលទាត់នៃយុវជនទ្វីបអាស៊ីក្រោមអាយុ ១៣ឆ្នាំ។ ស្ថិតនៅក្នុងក្រុម E និង ក្នុងអំឡុងពេល ៤ថ្ងៃ នៃការប្រកួត ក្រុមជម្រើសជាតិកម្ពុជាបានបង្ហាញមុខអនុស្សាវរីយ៍មានទាំងផ្អែមល្ហែម និង ជូរចត់ៗ ពីថ្ងៃដំបូង នៃការប្រកួត ក្រុមយុវជនអាយុក្រោម ១៣ឆ្នាំ អាចបង្ក្រាបភ្ញៀវបានៗ ជ័យជំនះ និង ការប្រកួតស្មើ បានធ្វើឱ្យអ្នកគាំទ្រសើចហ៊ោកញ្ជ្រៀវយ៉ាងខ្លាំងៗ គ្រាន់តែនៅថ្ងៃដំបូង ក្រុមកម្ពុជាអាចប្រកួតស្មើជាមួយក្រុមម៉ាឡេស៊ីក្នុងពិន្ទុ ០ ទល់នឹង ០ ឈ្នះហ្វីលីពីន ១ ទល់នឹង ០ ស្មើឥណ្ឌូនេស៊ី២ ទល់នឹង ២ ហើយឈ្នះម៉ាល់ឌីវ ២ ទល់នឹង ០។ សំរាប់ការប្រកួតសាកល្បងនូវបច្ចេកទេសក្នុងអំឡុងពេល ២ថ្ងៃ ដំបូង ក្នុង១ប្រកួតៗមានរយៈពេលតែ ២០នាទី ប៉ុណ្ណោះ។ លោក ម៉ី សុហ នាយកបច្ចេកទេសនៃសហព័ន្ធកីឡាបាល់ទាត់ឲ្យដឹងថាៈ "ផ្លូវតាមរយៈការប្រកួតចំនួន ៣លើក ក្រុមកុមារកម្ពុជាស្ថិតក្នុងលំដាប់ទី៣។ ប៉ុន្តែ នេះគឺគ្រាន់តែជាការគិតក្រៅផ្លូវការប៉ុណ្ណោះ ពីព្រោះកម្មវិធីនេះមិនមែនជាការប្រកួតពានរង្វាន់ទេ"។ សំរាប់ ២ថ្ងៃ ចុងក្រោយ ការប្រកួតនីមួយៗមានរយៈពេល ១ម៉ោង ដោយចែកចេញជា ២វគ្គ សំណើចរបស់អ្នកគាំទ្រកម្ពុជាបានរសាត់បាត់ទាំងស្រុងនៅពេលដែលក្រុមជម្រើសជាតិកម្ពុជាបានជួបបរាជ័យចំពោះមុខក្រុមម៉ាឡេស៊ីក្នុងលទ្ធផល ៦ ទល់នឹង ០។ អនុស្សាវរីយ៍អាក្រក់នេះគឺ នៅថ្ងៃចុងក្រោយ ដែលក្រុមកម្ពុជាបានចាញ់ក្រុមឥណ្ឌូនេស៊ី៦ទល់នឹង ១។ ទោះបីជាការប្រកួតមិនកម្មវិធីនេះ មានការបរាជ័យក្តី ដាក់ទីលានខុសពីស្រួចមុនៗក្តី ក៏ក្រុមយុវជនកម្ពុជាពុំបានបំពេញចិត្តអ្នកគាំទ្រឡើយៗ ហេតុដូច្នេះត្រូវបានពិពណ៌នាថា មកពីកីឡាករខ្មែរចុះចាញ់កំលាំង ពីព្រោះកម្មវិធីប្រកួតត្រូវបានធ្វើឡើងផ្ទួនៗគ្នាៗ លោកព្រុក ចាន់ណារ៉ា គ្រូបង្វឹកក្រុមយុវជនកម្ពុជាបានកត់សំគាល់ថាៈ "ដោយសារកម្មវិធីប្រកួតជាប់ៗគ្នាខ្លាំងពេកធ្វើឲ្យកីឡាករចុះកំលាំងៗ លោកបន្ថែមថា ការហ៊ឹកហ៊ឺនរបស់យើងមិនបានគ្រប់គ្រាន់ដូចគេទេៗ គួរកត់សំគាល់ថា នៅក្នុងមហាស្រពាលទាត់នេះ កីឡាករកម្ពុជាចាប់ផ្តើមបានយ៉ាងល្អដោយមានការហ្វឹកហាត់ត្រៀមមុនរយៈពេល ២ខែៗ ក្រុមយុវជនកម្ពុជាមិនអន់ដូចរៀមច្បងគេទេៗ ប៉ុន្តែនាំធ្វើដំណើររបស់ក្រុមយុវជន នៅឆ្ងាយទៀត ហើយវាអាចស្ថិតក្នុងលទ្ធផលល្អ ប្រសិនបើមានរន្ទះពិតក្នុងការអភិវឌ្ឍន៍វិស័យកីឡានេះៗ សមាគមសហព័ន្ធបាល់ទាត់អន្តរជាតិ FIFA បានទស្សន៍ទាយថា កម្ពុជាត្រូវការពេល ១០ឆ្នាំ ដើម្បីអភិវឌ្ឍន៍កីឡាបាល់ទាត់ រីឯស្ថាប័នបាល់ទាត់អន្តរជាតិ នៅប្រទេសស្វីស ជួយសហព័ន្ធខ្មែរកីឡាបាល់ទាត់ប្រមាណ ២៥០.០០០ដុល្លារអាមេរិក ក្នុង១ឆ្នាំ

បូលីន ដាវីដ

## ពានរង្វាន់បាល់ទាត់ថ្នាក់ជាតិចំនួន ៣ នឹងចាប់ផ្តើមក្នុងឆ្នាំនេះ

ទី១ ជាពានរង្វាន់ធំជាងគេ ហៅថា Cambodia Football League សំរាប់ក្រុមខ្លាំងខាងបាល់ទាត់ចំនួន ១០ ចាប់ប្រកួតនៅថ្ងៃទី ២៣ ខែមេសានេះៗ ទី២ ពានរង្វាន់យុវជនក្រោម ១៨ឆ្នាំ ដែលមាន ៨ក្រុម ចូលរួមប្រកួតចាប់ពីថ្ងៃទី ៤ ខែកញ្ញា ដែលធ្វើដំណាលគ្នានឹងពានរង្វាន់ ទី៣ សំរាប់យុវជនក្រោមអាយុ ១៦ឆ្នាំដែរៗ

## កម្ពុជាសមាជិកភាពអាស៊ាន

ថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០០៥នេះជាគម្រប់ខួបឆ្នាំទី៦ នៃការចូលជាសមាជិកអាស៊ានរបស់កម្ពុជាៗ អាស៊ានជាសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ៗ អង្គការនេះបានបង្កើតឡើងនាខែសីហា ឆ្នាំ១៩៦៧ៗ បច្ចុប្បន្នអាស៊ានមានសមាជិកភាពសរុបចំនួន ១០ប្រទេស រួមមាន ព្រុយណេ វៀតណាម ឡាវ ភូមា កម្ពុជា ថៃ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី សិង្ហបុរី ហ្វីលីពីនៗ ក្នុងរយៈពេល ៦ ឆ្នាំមកនេះ កម្ពុជាយើងទទួលបានអត្ថប្រយោជន៍ជាច្រើនលើវិស័យសេដ្ឋកិច្ច និង នយោបាយៗ

## បញ្ហាអន្តរជាតិ

# ប្រជាជនលីបង់បដិសេធការកាន់កាប់របស់ស៊ីរី

**ប្រទេសលីបង់ស្ថិតនៅទ្វីបអាស៊ីតំបន់មជ្ឈឹមបូព៌ា ដែលមានរាជធានីឈ្មោះថាបេរូតៗ ប្រទេសនេះមានប្រជាជន ៣លាននាក់ជាមួយនឹងផ្ទៃ ១០៤០០គម²ៗ**

ក្រោយពីព្រឹត្តិការណ៍នៃការធ្វើឃាតទៅលើអតីតនាយករដ្ឋមន្ត្រីលីបង់ រ៉ាហ្វិក ហារីរី កន្លងបានមួយខែនោះ ក៏មានការអំពាវនាវជាសាធារណៈ ឱ្យប្រទេសស៊ីរីបញ្ចប់ការកាន់កាប់របស់ខ្លួនមកលើប្រទេសលីបង់ៗ ប្រទេសបារាំង និង សហរដ្ឋអាមេរិកបានផ្តើមជំរុញឱ្យក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិអនុម័តលើដំណោះស្រាយ រិតត្បិតប្រទេសលីបង់ៗ កាលពីថ្ងៃទី ២ ខែកញ្ញា ឆ្នាំមុន (២០០៤) ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិបានអនុម័តចំពោះដំណោះស្រាយលេខ ១៥៥៩ ដើម្បីឱ្យទាហាន និង ភ្នាក់ងារស៊ើបការណ៍សម្ងាត់ របស់ស៊ីរី ចំនួន ១៥០០០នាក់ ដកថយចេញពីប្រទេសលីបង់ ជាបន្ទាន់ៗ ក្នុងករណីមិនព្រមដកកងទ័ពក្រុមប្រឹក្សាសន្តិសុខនេះ នឹងបង្កើតឱ្យមាននូវសំពាធ ជាអន្តរជាតិដើម្បីធ្វើការគាបសង្កត់មកលើប្រទេសស៊ីរីៗ នៅប្រមាណសប្តាហ៍ចុងក្រោយនេះ មហាបាតុកម្មដ៏ធំមួយបានផ្ទុះឡើងនៅទីក្រុងបេរូតប្រទេសលីបង់ៗ បាតុករចូលរួមមានប្រមាណជាង ១លាននាក់ បានគ្រវីទង់ជាតិ ដោយស្រែកថា "ស៊ីរីចេញទៅ"ៗ ក្រុមមេដឹកនាំប្រឆាំងបានស្វែងរកចំនួនមហាជនដ៏ច្រើនដើម្បីប្រកាសថា មានអាណត្តិជាសាធារណៈប្រឆាំងនឹងវត្តមានរបស់ប្រទេសស៊ីរី និងរដ្ឋាភិបាលបច្ចុប្បន្នៗ លោកនាយករដ្ឋមន្ត្រី លីបង់ អូម៉ាការ៉ាមី បានលាលែងពីតំណែងនៅថ្ងៃទី ២៨ ខែកុម្ភៈ ក្រោយព្រឹត្តិការណ៍ធ្វើឃាតលើ លោក ហារីរីៗ គេបាននឹងថា ការបោះឆ្នោតជ្រើសនាយករដ្ឋមន្ត្រីនឹងធ្វើឡើងនៅក្នុងពេលដ៏ខ្លីខាងមុខៗ លោកប្រធានអ្នកយកព័ត៌មានថាៈ "យើងសូមប្រកាសជាសាធារណៈថា យើងនឹងបង្កើតរដ្ឋាភិបាលរួមជាតិមួយ ហើយទាមទារនូវកិច្ចសន្យាពីគ្រប់ភាគីទាំងអស់"ៗ

សំ វ៉ានី





## របាយសាសនា

សាសនាគ្រិស្ត អ្នកកាន់និកាយ Maronite មានច្រើនជាងគេ បន្ទាប់មកមាននិកាយគ្រិកកាតូលិក គ្រិកអ័រតូដុក និង អ្នកកាន់ជំនឿ arménien ។ សំរាប់ឥស្លាមៈ អ្នកកាន់និកាយស៊ីអ៊ីតមានច្រើនជាងគេ បន្ទាប់មកមានស៊ុននីត និង Druze ។

# មក! យើងនាំគ្នារាំរបាំត្រុដិ

"ត្រុដិ" ជាពាក្យមកពីភាសាសំស្ក្រឹតមានន័យថា ផ្តាច់ ឬ កាត់ផ្តាច់ សំដៅដល់ការផ្តាច់ឆ្នាំចាស់ចូលឆ្នាំថ្មី មានព្រះរាជពិធីមួយហៅថា "ត្រស្តិសង្គ្រាន្ត"(១) ដែលពាក្យត្រស្តិនេះក្លាយពីពាក្យត្រុដិ


Photo: Kunthear

ការសម្តែងរបាំត្រុដិរបស់សមាគមសិល្បៈអម្ចាស់ដើម្បីបង្ហាញឱ្យទស្សនិកជនទស្សនាកំសាន្ត

## ប្រវត្តិរបាំត្រុដិ

ត្រុដិជារបាំប្រជាប្រិយមួយដែលធ្លាប់ឃើញមាននៅក្នុងខេត្តសៀមរាប និង ខេត្តផ្សេងៗ របាំនេះលេងពេលបុណ្យចូលឆ្នាំខ្មែរដើម្បីកំចាត់ចង្រៃ និង ប្រសិទ្ធពរជ័យជូនអ្នកស្រុកៗ ប៉ុន្តែ ជួនកាលរបាំនេះក៏មានលេងក្នុងពេលច្រូតកាត់ស្រូវហើយ ពេលស្រុកទេសជួបការរាំងស្ងួតផងដែរ តាមប្រសាសន៍របស់លោក អ៊ុត ចឺន អនុប្រធាននាយកដ្ឋានសិល្បៈទស្សនីយភាពបានឱ្យដឹងថា "របាំនេះគឺនៅសេសសល់ពីមនុស្សជំនាន់ដើមមួយពួក ដែលរស់នៅលើទឹកដីសុវណ្ណភូមិ ចាប់តាំងពីមុនទទួលបានអរិយធម៌ឥណ្ឌាមកម្ល៉េះ គឺជាពួកមនុស្ស ដែលអ្នកស្រុកហៅថា "ពួកសំរែ" ដែលរស់នៅភូមិភាគខាងជើងបឹងទន្លេសាប"។ លោកបានបន្តថា របាំនេះលេងនៅទីណាក៏បាន ឱ្យតែមានអ្នកចង់មើល មិនថានៅតាមវត្ត ភូមិអ្នកស្រុក តាមផ្ទះ ឬតាមទីជនបទៗ

## អំពីឧបករណ៍ និង អ្នកសម្តែង

របាំត្រុដិមានពីរក្រុម គឺក្រុមតូច និង ក្រុមធំ យោងទៅតាមការនិយមរបស់អ្នកស្រុក និង តាមចំនួនមនុស្សចូលលេង (១៣ ឬ ២៥នាក់)។ ឧបករណ៍សំរាប់លេងមាន៖ កញ្ចែ (ដងឈើពីរដងប្រវែង ២ម៉ែត្រ មានបន្ទះនាបតូចភ្ជាប់) ចង្រ្កង់ស្គរ ស្គរ ប៉ីតាកេ ទ្រអ៊ូ ទ្រសោ សន្ទូចលោ ចំពោះអ្នកលេងរបាំនេះមាន៖ មនុស្សប្រុស ព្រាននំព្រៃ អ្នកកាន់ដងដោយ(រាងដូចជន្ទាប់ទេះ) អ្នកវាយស្គរ ២នាក់ ក្ងោក ២នាក់ យក្ស ២នាក់ ព្រាយស្រីក្របកបើង ២នាក់ មនុស្សទន្សោង អ្នកកាន់ដងកញ្ចែ និង អ្នកច្រៀងម្នាក់ៗ

(១) ត្រស្តិត្រស់ៈ ព្រះរាជពិធី១ប្រភេទធ្វើនៅវេលាយប់១៤ រោច ខែ ផល្គុនៗ សង្ក្រាន ឬ សង្ក្រាន្តិ គឺជាដំណើរឃ្លាតចាកទី ឬ ដំណើរដាច់ឆ្នាំចាស់ផ្លាស់ឆ្នាំថ្មី

មុំ គន្ធា

### ជំនឿរបស់អ្នកលេងរបាំត្រុដិ

មុននឹងចេញលេងគេត្រូវតែបណ្តាក់ថ្វាយព្រះភិក្ខុស្រុកជាមុនសិនទើបបានៗ ជំនឿ១ទៀត ចំពោះស្រ្តីមានប្តី បើចង់លេងត្រុដិគឺត្រូវសុំអនុញ្ញាតប្តីជាមុនសិនដោយត្រូវរៀបស្លាម្លូ ធូប ទៀនធូប និងផ្កា ៥ គូ ដាក់លើជើងពាន ក្រាបសំពះស្វាមីថា "ខ្ញុំសុំលាទៅលេងត្រុដិ"។



# ចូលឆ្នាំហើយ! នាំគ្នាលេងអ្វី?

ល្បែងប្រជាប្រិយខ្មែរមានច្រើន ដែលប្រជាពលរដ្ឋនិយមលេងកំសាន្តក្នុងថ្ងៃចូលឆ្នាំ។ នៅពេលនេះ អ្នកនាំសារ សូមបង្ហាញនូវឈ្មោះ និង របៀបលេងមួយចំនួនសំរាប់លេងកំសាន្តនាបុណ្យចូលឆ្នាំ

**ល្បែងចោលឈូង៖** គេច្រើនលេងនៅយប់ខែភ្លឺក្នុងថ្ងៃចូលឆ្នាំថ្មី(ខែចេត្រ_ពិសាខ)។ ការលេងឈូងចែកជា ២ បែប គឺ ឈូងច្រៀងរាំ និង ឈូងលោះខ្ញុំ។ ឈូងច្រៀងរាំ ដំបូងខាងប្រុសបោះឈូងទៅឱ្យខាងស្រី។ ខាងស្រីប្រុងចាប់ កុំឱ្យធ្លាក់ដល់ដី បើធ្លាក់ចាត់ជាស្លាប់។ គេផ្តើមបោះទៅឱ្យខាងប្រុសវិញ ខាងប្រុសប្រុងចាប់កុំឱ្យធ្លាក់ដែរ។ កាលណាចាប់បាន ត្រូវចោលសំដៅទៅខាងស្រី បើខុសចាត់ជាស្លាប់។ បើចោលត្រូវស្រីណាហើយ ស្រីនោះច្រៀងរាំយកឈូងជូនខាងប្រុស។ ឯឈូងលោះខ្ញុំ ដំបូងខាងប្រុសច្រៀង ១ ទំនុក។ ច្រៀងហើយក៏បោះឈូងទៅខាងស្រី។ បើខាងស្រីចាប់ឈូងបានចោលទៅខាងប្រុស បើត្រូវប្រុសណា ត្រូវចាប់យកមកទុក។ បើខាងប្រុសចាប់ឈូងបានចោលមកខាងស្រីវិញ ត្រូវនារីណា ប្រុសដែលស្រីចាប់បានពីមុនត្រូវបានរួចខ្លួន។ បើចោលមិនត្រូវ ប្រុសនោះត្រូវនៅខាងស្រីដដែល។

**ល្បែងលាក់កន្សែង៖** គេតែងលេងនៅខែភ្លឺថ្ងៃចូលឆ្នាំ ឬ ក្រោយពេលសំរាកពីហាត់នឿយម្តងៗ។ អ្នកលេងមានពី ៦_៧ នាក់ឡើងទៅ អង្គុយពែនជារង្វង់មូល រួចដាក់ដៃទាំងពីរលើក្បាលជង្គង់ដោយមិនឱ្យងាក ឬ លួចមើលមកក្រោយទេ។ គេយកកន្សែង ឬ ក្រមាមួយមករុំម្សៀតឱ្យតឹងណែនល្អទុកជាបន្តិចសំរាប់វាត់។ បើអ្នកដែលត្រូវគេលាក់កន្សែងមិនដឹងខ្លួន ហើយអ្នកដែលលាក់នោះយកកន្សែងបានម្តងទៀត អ្នកលាក់នោះជាអ្នកឈ្នះ។ តែបើអ្នកអង្គុយដឹងខ្លួនហើយចាប់យកកន្សែងបានមុននោះ គេទុកអ្នកនោះឈ្នះ។

**ល្បែងបោះអង្គុញ៖** លេងបានទាំងប្រុស ស្រី ចាស់ ក្មេងៗ ល្បែងនេះលេងបានពី ២នាក់ឡើងទៅ ដោយចែកចេញជា ២ពួក មានចំនួនស្មើគ្នា មានស្រីម្ខាងប្រុសម្ខាង ឬ អាចចុះគ្នាបានៗ អង្គុញក៏ចែកចេញជាពីរផ្នែកដែរ គឺកាយដាំ និង កាយបោះៗ

មុំ គន្ធា

### ល្បែងប្រជាប្រិយផ្សេងៗ

មានដូចជា ស្តេចចង់ ចាប់កូនមាន់ បិទភ្នែក ទាញព្រ័ត្រ វាយឆ្នាំង ។ល។ លោកយាយតង់ អាយុ៧០ឆ្នាំមានប្រសាសន៍ឱ្យដឹងថា "យុវជន_នារីខ្មែរនិយមលេងល្បែងទាំងនេះណាស់ ព្រោះជាល្បែងខ្មែរតាំងពីបុរាណ ហើយពេលលេងគឺធ្វើឱ្យស្នេហ៍ពាក់ព័ន្ធប្រពៃណីខ្មែរ"។


Photo: P. Samphy

យុវសិស្សមហាវិទ្យាល័យកំពុងយកពេលទំនេរលេងល្បែងប្រជាប្រិយប្រពៃណីបែងចែកកាយ

## មុខរបរ

**អាជីពខាងការដើរបង្ហាញម៉ូតកំពុងតែមានការរីកចម្រើនស្របតាមការរីកចំរើនសង្គមសម័យទំនើបៗ អ្នកដើរម៉ូតែងមានរូបរាងស្អាត ដែលធ្វើឱ្យមហាជនចាប់អារម្មណ៍ស្នេហ៍គេ**



Photo: Sapors

# អាជីពដើរម៉ូដ

### ការងារ

បង្ហាញម៉ូដគឺជាមុខរបរមួយដែលត្រូវការសោភ័ណភាព ជាចាំបាច់ៗ អ្នកបង្ហាញម៉ូដ ទោះប្រុស ឬ នារី ការសម្តែងលើឆាក ជាការដើរឱ្យបានសមរម្យបំផុត ពីព្រោះគេត្រូវបង្ហាញម៉ូដសំលៀកបំពាក់ដែលទើបនឹងរចនាឡើងថ្មីៗ ពេលខ្លះគេច្រើនឃើញផ្សាយផលិតផលឱ្យក្រុមហ៊ុនជំនួញនានា ដូចជា ក្រុមហ៊ុនទូរស័ព្ទ ក្រុមហ៊ុនសំអាងការ និងក្រុមហ៊ុនចំណីអាហារៗលៗ និង ។លៗ ដោយសារតែកិច្ចការត្រូវប្រឈមនៅចំពោះមុខមហាជនច្រើន អ្នកបង្ហាញម៉ូដត្រូវតែថែរក្សាសម្ផស្សរបស់ខ្លួនឱ្យបានស្អាតជានិច្ចៗ អ្នកស្រី សាពាណ៍ រេន ដល ប្រធានសាលាបង្ហាញម៉ូដ និង កែសម្ផស្សសាពាណ៍ បានមានប្រសាសន៍ថា "ដើម្បីធ្វើជាអ្នកបង្ហាញម៉ូដល្បីបានទាល់តែយើងមានទំនុកចិត្តលើអាជីពនេះ និងមានសម្ផស្សល្អស្អាតផងខ្លះផងដែរៗ លើសពីនេះយើងត្រូវព្យាយាមហាត់ដើរពត់អាកប្បកិរិយា និង ថែរាងកាយឱ្យបានល្អ"ៗ

### ប្រាក់ចំណូល

អ្នកបង្ហាញម៉ូដថ្មីថ្មោង គេអាចយកចំនួនបាន ២០ ដុល្លារក្នុងរយៈពេលសម្តែងពី ១០ ទៅ ២០ នាទី នៅក្នុងពិធីបង្ហាញសំលៀកបំពាក់ ឬ ផ្សព្វផ្សាយផលិតផលនានាៗ លុះគេធ្វើការបានមួយរយៈ (ភាគច្រើន ១ឆ្នាំ) ប្រាក់អាចកើនបានពី ៥០ ទៅ ៦០ ដុល្លារ ដោយអាស្រ័យលើបទពិសោធន៍ ទេពកោសល្យ និង ភាពស្ទាត់ជំនាញរបស់គេចំពោះការសំដែងៗ

### ពត៌មានសិក្សា

ដើម្បីក្លាយខ្លួនទៅជាអ្នកបង្ហាញម៉ូដ យើងអាចទៅសិក្សានៅសាលាសាពាណ៍បង្ហាញម៉ូដ និង កែសម្ផស្ស នៅរាជធានីភ្នំពេញៗ រយៈពេលសិក្សាគឺមានពី ៣ ទៅ ៤ ខែ ដោយផ្តោតជាសំខាន់លើការរៀនដើរ ដោយក្នុងមួយខែៗ យើងត្រូវចំណាយអស់ ៣០ ដុល្លារៗ ប៉ុន្តែ មុននឹងចូលសិក្សាយុវជន_នារីត្រូវទាមទារឱ្យមានរូបសម្បត្តិស្រស់ស្អាតៗ

ផាត សំភី

### សាលាសាពាណ៍បង្ហាញម៉ូដ

សាលាសាពាណ៍នេះបើកទ្វារតាំងពីឆ្នាំ១៩៩៦ មានបង្រៀនមុខជំនាញផ្សេងៗ ដូចជា ដើរម៉ូដ សំអាងការ និងស៊ីជីម៉ូក្នុងការរស់នៅ ទំនាក់ទំនងទូរស័ព្ទ ០១២ ៨០៣ ៥២៩



រូបលើ៖ បើប្អូនៗ ចង់ដឹងថា តើកូនដំរីតូចដ៏គួរឱ្យស្រលាញ់នេះ
កំពុងធ្វើអ្វី សូមគូសភ្ជាប់ចំនុចតូចៗពី លេខ ១ ដល់ លេខ ៣៥។
រូបក្រោម៖ សូមប្អូនៗប្រើពណ៌ ផាត់ល្អិតភាពតាមតែប្អូនចូលចិត្ត។



គំនូរ ៖ ក. ចន្ទ ពិសី

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក ផ្ទះលេខ ៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត រាជធានីភ្នំពេញ
Tel/Fax: (855) 23 224 120 E-mail: csc@catholiccambodia.org
អភិបាលគ្រប់គ្រង៖ លោកអភិបាល អេមីល ដេតុំប អគ្គនាយក៖ លោកបូជាចារ្យ រ៉ូម៉ែរ ហ្វ៊ីរ៉ាល់ដូ